ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៦៥
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨
-សាលក្រមអង្គសេចក្ដីលេខៈ ៦៨ "ធ"
ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ៤ និង ៥០នាទីល្ងាច ដោយមានសមាសភាពចូលរួមដូចតទៅៈ

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តតាកែវ

### តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៦៥ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទៈ

-ឈ្មោះ [redacted] ស៊ីណុប ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] នី (ស្លាប់) ម្ដាយឈ្មោះ [redacted] អឹម (ស្លាប់) មានប្រពន្ធឈ្មោះ [redacted] ដេត មានកូន ០៤នាក់ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការៈ គ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិថ្មី ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ កាលពីអំឡុងឆ្នាំ២០១០ បទល្មើសដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោក [redacted] មានអត្តលេខៈ [redacted] និងលោក [redacted] ជាមេធាវីការពារក្ដីឱ្យជនជាប់ចោទ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទរះ ភេទប្រុស អាយុ២៣ឆ្នាំ មានទីលំនៅភូមិថ្មី ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។

លេខៈ ០១១៨ ដែលជាអតីតដីរបស់ខ្ញុំបាទទៅលក់ឱ្យឈ្មោះ [redacted] លីជា ដែលត្រូវជាក្មួយរបស់ខ្ញុំបាទ ក្នុងតម្លៃ ៧,៥០០$ ដើម្បីយកទៅមើលជំងឺម្ដាយរបស់គេឈ្មោះ [redacted] វាសនា តែដោយកាលពេលនោះ ក្បាលដីលេខៈ ០១១៨ គឺជាដីរបស់ខ្ញុំបាទ ហើយម្ដាយឈ្មោះ [redacted] ច័ន្ទរះ ក៏បានមកអង្វរឱ្យខ្ញុំបាទចេញ មុខជាអ្នកជួយលក់ដីឱ្យទៅឈ្មោះ [redacted] លីជា ដោយសារតែខ្ញុំបាទមានមនោសញ្ចេតនាខ្ញុំបាទក៏យល់ ព្រមទៅ និងបានចេញឈ្មោះជាអ្នកជួយលក់លើក្បាលដីលេខៈ ០១១៨ ឱ្យទៅឈ្មោះ [redacted] លីជា បាន ប្រាក់ចំនួន ៧,៥០០$ ដែលមានលោកយាយឈ្មោះ [redacted] សុខ គាត់ជាអ្នកទទួលលុយនោះ។ ក្រោយ មកឈ្មោះ [redacted] ច័ន្ទរះ បានដាក់ពាក្យបណ្ដឹងទប់ស្កាត់លើក្បាលដីលេខៈ ០១១៨ ដោយមិនធ្វើការផ្ទេរ បានឡើយ។ ហើយឈ្មោះ [redacted] លីជា ក៏បានឈប់ទិញដីខាងលើនេះវិញ ដោយឈ្មោះ [redacted] លីជា ក៏ បានសម្រេចចិត្តលក់ក្បាលដីលេខៈ ០១១៨ នោះទៅឱ្យឈ្មោះ [redacted] វាសនា ក្នុងតម្លៃ ៧,៥០០$ វិញ ដើម្បីគេឈប់ពាក់ព័ន្ធ។ ចំពោះឈ្មោះ [redacted] ច័ន្ទរះ គឺគេត្រូវជាចៅទួតរបស់លោកតា ផេង សៀម និង លោកយាយ [redacted] ង៉ែត ហេតុដូច្នេះចំពោះពាក់ព័ន្ធនឹងបញ្ហានៃដីខាងលើនេះ គឺតុលាការសាលាឧទ្ធរណ៍ បានសម្រេចរួចរាល់អស់ហើយ ដោយឈ្មោះ [redacted] ច័ន្ទរះ មិនមានសិទ្ធិអ្វីលើដីទាំងនេះនោះទេ។

-ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទរះ បានឆ្លើយថាៈ ខ្ញុំបាទត្រូវជាចៅទួតរបស់លោក តាឈ្មោះ [redacted] សៀម និងលោកយាយឈ្មោះ [redacted] ង៉ែត និងត្រូវជាកូនរបស់ឈ្មោះ [redacted] វាសនា ដែល ម្ដាយឈ្មោះ [redacted] វាសនា ត្រូវជាចៅរបស់លោកតា [redacted] សៀម និងលោកយាយ [redacted] ង៉ែត ហើយម្ដាយ របស់ខ្ញុំបាទត្រូវជាកូនរបស់ឈ្មោះ [redacted] ណាន និងលោកយាយឈ្មោះ [redacted] សុខ ។ ហើយចំពោះពាក់ ព័ន្ធនឹងដីខាងលើនេះ គឺមូលហេតុដែលខ្ញុំបាទបានប្ដឹងលើឈ្មោះ [redacted] ស៊ីណុប បានដកដីដែលម្ដាយខ្ញុំ បាទបានទទួលដីពីលោកតាទួតឈ្មោះ [redacted] សៀម និងលោកយាយទួតឈ្មោះ [redacted] ង៉ែត ទៅលក់ ឱ្យឈ្មោះ [redacted] លីជា ដោយបានយកប្ដូរដីទៅលក់ឱ្យទឈ្មោះ [redacted] លីជា ទាំងដែលមិនបានប្រាប់ខ្ញុំអ្វី បន្តិចសោះ។ ដោយឈ្មោះ [redacted] ស៊ីណុប មិនបានឱ្យលុយនៃការទិញលក់ដីរវាងក្បាលដីលេខៈ ៩៤៤ ជាមួយនឹងក្បាលដីលេខៈ ០១១៨ ចំនួន ១០,០០០$ នោះមកឱ្យខ្ញុំបាទដែលត្រូវជាចៅទួត និងម្ដាយខ្ញុំ បាទនោះទេ។ ហើយចំណែកឯក្បាលដីលេខៈ ០១១៨ ដែលឈ្មោះ [redacted] ស៊ីណុប បានដូរជាមួយនឹង ក្បាលដីលេខៈ ៩៤៤ នោះក៏ឈ្មោះ [redacted] ស៊ីណុប មិនបានប្រគល់ឱ្យមកខ្ញុំបាទនោះដែរ។ រឿងហេតុ ដែលខ្ញុំបាទប្ដឹងនេះ គឺខ្ញុំមិនសុខចិត្តនឹងឈ្មោះ [redacted] ស៊ីណុប មិនបានឱ្យលុយចំនួន ១០,០០០$ និង ក្បាលដីលេខៈ ០១១៨ ឱ្យមកខ្ញុំបាទដែលជាចៅតួតនោះទេ។ ចំពោះការលក់ដូរ និងដូរប្ដូរនៃក្បាលដី លេខៈ ៩៤៤ និងដូរក្បាលដីលេខៈ ០១១៨ នោះ គឺកាលពីអំឡុងឆ្នាំ២០១០ ហើយក្រោយមកនៅក្នុង អំឡុងឆ្នាំ២០១០ នោះដដែលលោកតា និងលោកយាយរបស់ខ្ញុំបាទក៏បានទទួលមរណភាពបាត់ទៅ។ ក្រោយមកនៅក្នុងឆ្នាំ២០១៨ នេះទើបខ្ញុំបាទបានដាក់ពាក្យបណ្ដឹងតែម្ដង។ ខ្ញុំបាទសូមបញ្ជាក់ថាៈ ចំពោះដីទំនាស់ខាងលើនេះ គឺមិនទាន់មានការកំណត់ និងសម្រេចអំពីអ្នកដែលមានសិទ្ធិគ្រប់គ្រងលើដី របស់លោកតាទួតឈ្មោះ [redacted] សៀម និងលោកយាយទួតឈ្មោះ [redacted] ង៉ែត នោះទេ។ ចំពោះការទិញ លក់ និងដូរដីជាមួយនឹងលោកតាទួតឈ្មោះ [redacted] សៀម និងលោកយាយទួតឈ្មោះ [redacted] ង៉ែត នោះ ជាមួយនឹយឈ្មោះ [redacted] ស៊ីណុប នោះ គឺខ្ញុំបាទបានដឹងថាលោកតាទួត និងលោកយាយទួតបានលក់ និង

ជនរបស់សហព័ទ្ធដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនជានិច្ច។ ដូច្នេះបញ្ជាក់ថាៈ ឈ្មោះ [redacted] សុខ មានអាយុ៦២ឆ្នាំ ជាអ្នកដែលមានសិទ្ធិទទួលបន្តនូវមរតករបស់មតកជនលោកតា ផែង សៀម និងលោកយាយ អ៊ុក ង៉ែត។ ហើយចំពោះការប្តឹងចោទប្រកាន់នេះដែរ គឺកូនក្តីខ្ញុំបាទមិនមានការពាក់ព័ន្ធនឹងអង្គហេតុដែលឈ្មោះ [redacted] ច័ន្ទរ៉ះ បានប្តឹងនេះដែរ ហើយក៏ពុំមានភស្តុតាងណាមួយ ឬសាក្សីណាមួយបញ្ជាក់ថាកូនក្តីខ្ញុំបាទប្រព្រឹត្តអំពើខាងលើនេះនោះដែរ។ យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថាៈ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ហេតុផលទាំងអស់នេះបញ្ជាក់ឱ្យឃើញថា គឺមិនមានភស្តុតាងដាក់បន្ទុកណា ឬសាក្សីណាមួយដែលបញ្ជាក់ថាៈកូនក្តីខ្ញុំបាទកូនក្តីខ្ញុំថាកូនក្តីខ្ញុំបាទបានប្រព្រឹត្តបទល្មើសរំលោភលើទំនុកចិត្តនោះទេ និងយាយរួម គឺមិនមានអង្គហេតុទាល់តែសោះដែលថាកូនក្តីខ្ញុំបាទបានពាក់ព័ន្ធនឹងឈ្មោះ [redacted] ច័ន្ទរ៉ះ នោះទេ គឺឈ្មោះ [redacted] ច័ន្ទរ៉ះ ជាអ្នកបង្កើតអង្គហេតុចោទប្រកាន់ខ្លួនឯងតែប៉ុណ្ណោះ។ ហេតុដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីណុប ដោយទី១.សុំឱ្យតុលាការទទួលស្គាល់នូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំបាទចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២, ទី២.សុំបដិសេធលើពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ច័ន្ទរ៉ះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ និងទី៣.ស្នើសុំដល់តុលាការមេត្តាសម្រេចឱ្យកូនក្តីខ្ញុំបាទបានរួចផុតពីបទចោទប្រកាន់ខាងលើនេះ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណុប ថាៈ សុំដល់តុលាការសម្រេចឱ្យរូបខ្ញុំបាទរួចផុតពីការចោទប្រកាន់ខាងលើនេះ ដោយហេតុថាខ្ញុំបាទមិនមានការពាក់ព័ន្ធជាមួយនឹងឈ្មោះ [redacted] ច័ន្ទរ៉ះ នោះទេ ហើយខ្ញុំបាទក៏ពុំបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់នោះដែរ។

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបាន ស្តាប់ចម្លើយបំភ្លឺរបស់សាក្សី។

-ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបាន ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ ។

## សំអាងហេតុ

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខៈ ៤១១៧ ជ.ជ.រ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ដោយបានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ស៊ីណុប ភេទប្រុស អាយុ៤៨ឆ្នាំ មកជំនុំជម្រះពីបទៈ រំលោភលើទំនុកចិត្ត បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២-តាមចម្លើយរបស់ជនជាប់ចោទជាប់ចោទឈ្មោះ [redacted] ស៊ីណុប និងចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] លីដា ព្រមទាំងការពិនិត្យលើពាក្យសុំចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ របស់លោកយាយឈ្មោះ

ក្បាលដីលេខៈ ០១១៨ រួចហើយឈ្មោះ [redacted] លីដា ក៏ចង់កាត់ប្លង់ផ្ទេរកម្មសិទ្ធិពីម្ចាស់ដីដើមមកខ្លួនជាម្ចាស់កម្មសិទ្ធិ ក៏ប៉ុន្តែមិនអាចធ្វើការផ្ទេរកម្មសិទ្ធិបាននោះទេ ដោយហេតុថាមានឈ្មោះ [redacted] ច័ន្ទរះ ត្រូវជាចៅបានសុំរក្សាការពារនៅលើក្បាលដីលេខៈ ០១១៨ និងបានប្តឹងទាមទារយកក្បាលដីនេះមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន រួចហើយឈ្មោះ [redacted] លីដា មិនចង់មានរឿងរ៉ាវវែងឆ្ងាយ ក៏បានសម្រេចចិត្តផ្ទេរ និងលក់ក្បាលដីលេខៈ ០១១៨ ឱ្យទៅឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] វាសនា វិញ ដោយមានឈ្មោះ [redacted] ស៊ីណុប ជាអ្នកដែលឈរឈ្មោះទិញដដែលវិញ ដោយហេតុថាក្បាលដីលេខៈ ០១១៨ គឺមានកម្មសិទ្ធិករឈ្មោះ [redacted] ស៊ីណុប នៅលើប្លង់ដីនោះតាំងពីដើម។ ហើយឈ្មោះ [redacted] ស៊ីណុប ក៏បានយល់ព្រម និងបានឈរឈ្មោះធ្វើជាអ្នកទិញដីនោះពីឈ្មោះ [redacted] លីដា ដើម្បីយកទៅឱ្យឈ្មោះ [redacted] សុខ វិញ។ ក្រោយមកក៏មានការបន្តការប្តឹងទាមទារដីខាងលើនេះ (ក្បាលដីលេខៈ ០១១៨) ពីសំណាក់ឈ្មោះ [redacted] ច័ន្ទរះ ចូលមកសាលាដំបូងខេត្តតាកែវ ដោយសុំឱ្យតុលាការសម្រេចផ្ទេរក្បាលដីលេខៈ ០១១៨ (ឈ្មោះកម្មសិទ្ធិករ [redacted] ស៊ីណុប (ជាប្តីនាង [redacted] ង៉ែត) ឱ្យមកខ្លួន និងម្តាយឈ្មោះ [redacted] វាសនា ជាម្ចាស់កម្មសិទ្ធិ និងក្បាលដីលេខៈ ០៩៤៤ (ឈ្មោះកម្មសិទ្ធិករ [redacted] សៀម និងនាង [redacted] ង៉ែត) ឱ្យទៅឈ្មោះ [redacted] ស៊ីណុប ជាម្ចាស់កម្មសិទ្ធ ហើយសាលាដំបូងខេត្តតាកែវក៏បានសម្រេចតាមការទាមទារនេះដោយបានចេញសាលក្រមរដ្ឋប្បវេណីលេខៈ ២២៦ (ក) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។ បន្ទាប់មកក៏មានឈ្មោះ [redacted] សុខ ដែលត្រូវជាម្តាយរបស់ឈ្មោះ [redacted] វាសនា និងត្រូវជាយាយរបស់ឈ្មោះ [redacted] ច័ន្ទរះ បានប្តឹងសុំឱ្យជំនុំជម្រះសាលក្រមរដ្ឋប្បវេណីលេខៈ ២២៦ (ក) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តតាកែវវិញ និងសុំឱ្យប្រគល់ក្បាលដីលេខៈ ០១១៨ ឱ្យទៅឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] វាសនា តាមចំណែកជាម្ចាស់កម្មសិទ្ធិវិញ ហើយសាលាដំបូងខេត្តតាកែវក៏បានចេញដីកាសម្រេចលេខៈ ៧២២ (ក) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដោយបានសម្រេចតាមការទាមទាររបស់ឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] វាសនា។ បន្តមកទៀតក៏មានឈ្មោះ [redacted] ច័ន្ទរះ មិនសុខចិត្តនឹងជំទាស់នឹងដីកាសម្រេចលេខៈ ៧២២ (ក) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដោយបានប្តឹងទៅសាលាឧទ្ធរណ៍ភ្នំពេញ ហើយសាលាឧទ្ធរណ៍ភ្នំពេញក៏បានចេញដីកាសម្រេចលេខៈ១៥ ដកស "ខ" ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ ដោយបានសម្រេចបញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខៈ៣៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញមកសាលាដំបូងខេត្តតាកែវឱ្យធ្វើការចាត់ការ និងកំណត់អំពីចំណុចវិវាទនៃរឿងក្តីនេះឡើងវិញ។

៣-តាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណុប ដែលបានឆ្លើយថាៈ ខ្លួនមិនបានប្រព្រឹត្តអំពើខាងលើដូចការចោទប្រកាន់នោះទេ ចំពោះក្បាលដីលេខៈ ០៩៤៤ គឺខ្លួនពិតជាបានព្រមព្រៀងទិញពីឈ្មោះ [redacted] សៀម និងប្រពន្ធឈ្មោះ [redacted] ង៉ែត ក្នុងតម្លៃ ១៧,០០០$ ពិតប្រាកដមែន ហើយខ្លួនបានប្រគល់ប្រាក់ចំនួន ១០,០០០$ ឱ្យទៅតាឈ្មោះ [redacted] សៀម និងប្រពន្ធឈ្មោះ [redacted] ង៉ែត រួចហើយ។ ចំណែកឯប្រាក់ដែលនៅសល់ចំនួន ៧,០០០$ គឺខ្លួនបានព្រមព្រៀងជាមួយនឹងតាឈ្មោះ [redacted] សៀម និងប្រពន្ធឈ្មោះ [redacted] ង៉ែត ដោយកាត់ដីដែលមានក្បាលដីលេខៈ ០១១៨ ឱ្យទៅគាត់វិញ។ ដែលចម្លើយនេះអាចឱ្យតុលាការជឿជាក់បានដោយហេតុថាៈ ក្រោយពីការទិញលក់ដោះដូរដីគ្នារួចហើយនោះ គឺភាគីទាំងសងខាងបានធ្វើការគ្រប់គ្រងកាន់កាប់លើដីដែលពួកខ្លួនបានព្រមព្រៀងគ្នានោះ



Scanned with CamScanner

នេះ។ ក្នុងករណីនេះតុលាការយល់ឃើញថា: ការសន្និដ្ឋានសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់។ គប្បីតុលាការទទួលយកមកពិចារណា។

## **ហេតុដូច្នេះសម្រេច**

-ឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីណុប ភេទប្រុស អាយុ៤៩ឆ្នាំ (អត្តសញ្ញាណខាងលើ) រួចខ្លួនពីបទចោទបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិថ្មី ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ កាលពីអំឡុងឆ្នាំ ២០១០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រ ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទរះ និងជនជាប់ចោទឈ្មោះ [redacted] ស៊ីណុប។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

---

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃចន្ទ ១០រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

បានឃើញ
តាកែវ,ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២
**ចៅក្រមជំនុំជម្រះ**

[redacted]

តាកែវ,ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២
**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner